# អំពីឈ្មោះ “ព្រះធាតុបារាយណ៍”

ព្រះធាតុបារាយណ៍ គឺជាឈ្មោះប្រាសាទមួយដែលមានទីតាំងស្ថិតនៅក្នុងភូមិបន្ទាយ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចម្ងាយប្រមាណ ១,៥គ.ម.អាគ្នេយ៍ឃុំបារាយណ៍។ ប្រាសាទនេះមានប៉មមួយរាងបួនជ្រុងស្មើ មានទ្វារចូលនៅទិសខាងកើតនិងខាងលិច រីឯនៅមុខខាងជើងនិងខាងត្បូងគេលម្អជាទ្វារបញ្ឆោត (រូបលេខ១-២)។[១] ប្រាសាទនេះទំនងជាប្រាសាទចាស់ដែលសាងឡើងនៅស.វ.ទី១១ ហើយលោក Jean Boisselier យល់ថា នៅសម័យក្រោយអង្គរគេបានប្រើប្រាស់សម្ភារៈចាស់យកមកប្រើប្រាស់ឡើងវិញដើម្បីសាងបន្ថែម។[២] សព្វថ្ងៃគេបានសាងជាដំបូលប្រក់ការពារពីលើទៀតផង។ នៅព្រះធាតុបារាយណ៍ មាននៅសេសសល់វត្ថុសិល្បៈចាស់ៗជាច្រើន ជាពិសេសគឺចម្លាក់រឿងទេវកថាព្រហ្មញ្ញសាសនា ដូចជាឈុតព្រះនារាយណ៍ផ្ទុំ[៣] ឈុតព្រះឥសូររាំ[៤] (រូបលេខ៣) ឈុតកូរសមុទ្រទឹកដោះ[៥] (រូបលេខ៤) ឈុតរឿងរាមកេរ្តិ៍ ត្រង់ពាលី និងសុគ្រីពប្រយុទ្ធគ្នា[៦] (រូបលេខ៥) ឈុតព្រះក្រឹស្ណទ្រភ្នំគោវធ៌ន[៧] (រូបលេខ៦)។ល។ តើ “ព្រះធាតុបារាយណ៍” ទំនងមានន័យយ៉ាងណាទៅវិញ?

សូមជ្រាបថា ចាប់ពីស.វ.ទី១៤មក ឥទ្ធិពលព្រះពុទ្ធសាសនាថេរវាទបានជ្រួតជ្រាបខ្លាំងក្នុងសង្គមខ្មែរ ហើយខ្មែរបានចាត់ទុកប្រាសាទពីមុនមកស្ទើរតែទាំងអស់ជាទីពុទ្ធបូជា ហើយប្រាសាទមួយចំនួនច្រើនតែមានន័យស្មើនឹងចេតិយ។ ជួនកាល គេបានកែប្រែរូបរាងប្រាសាទទៅជាចេតិយក៏មានច្រើន ហើយពេលនោះហើយទើបគេនិយមហៅប្រាសាទថា “ព្រះធាតុ” ទៅវិញ ព្រោះ “ព្រះធាតុ” មានន័យថា “ចេតិយ” (កន្លែងសម្រាប់ដាក់ធាតុ)។[៨] ពេលនោះហើយដែលខ្មែរបានចាប់ផ្តើមនិយមហៅប្រាសាទថា “ព្រះធាតុ” វិញ។ ឧទាហរណ៍ ព្រះធាតុខ្វាវ ព្រះធាតុបាយក្រៀម ព្រះធាតុដកព ព្រះធាតុក្តម្ព ព្រះធាតុកញ្ឆៀច ព្រះធាតុព្រះស្រី ព្រះធាតុព្រៃជើងស្រុក ព្រះធាតុមេបុណ្យ

KHMER CIVILIZATION

---

[១] Lajonquière 1901: 161; Dalet 1936: 27.

[២] Boisselier 1966: 97.

[៣] Bénisit 1965: 101.

[៤] Roveda 2005: 162-163.

[៥] Thomas 1999: 93.

[៦] Roveda 2005: 58-61.

[៧] Randhawa 1965: 5; Roveda 2005: 80-89.

[៨] ព្រាប ចាន់ម៉ារ៉ា ២០១២: ២៩។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ព្រះធាតុក្ងាន់ពីរ ព្រះធាតុធំ ព្រះធាតុសម្ដី ព្រះធាតុស្រម ព្រះធាតុធំ ព្រះធាតុតូច ព្រះធាតុរកា ព្រះធាតុត្រពាំងជ្រៃ ។ល។

ចុះពាក្យ "បារាយណ៍" មានន័យយ៉ាងណាទៅវិញ?

ជាទូទៅ កាលណាគេនិយាយអំពីពាក្យ "បារាយណ៍" គេច្រើននឹកឃើញដំបូងគេទៅលើអាងស្តុកទឹក ដ្បិត នៅខេត្តសៀមរាបមានអាងស្តុកទឹកដ៏ធំមួយនៅខាងលិចអង្គរ គេហៅថា "បារាយណ៍ខាងលិច" ឬ "បារាយណ៍ទឹកថ្លា"។ ប៉ុន្តែ ប្រសិនបើយើងយកមកគិតឡើងវិញ កាលដែលយល់ថា "បារាយណ៍" មានន័យទាក់ទងនឹងអាងស្តុកទឹកទំនងមិនត្រឹមត្រូវទេ។ ដ្បិត នៅក្នុងសិលាចារឹកខ្មែរបុរាណ យើងពុំធ្លាប់ជួបសិលាចារឹកណាដែលនិយាយថាអាងស្តុកទឹកគេបានហៅថា "បារាយណ៍" នោះឡើយ។ ពាក្យដែលទាក់ទងនឹងអាងស្តុកទឹកធ្លាប់ជួបក្នុងសិលាចារឹកមានដូចជា បឹង ត្រពាំង ទន្លេ ស្ទឹង ប្រឡាយ ចង្ហូរ អន្លង់ ឆោក អញ្ចូន ល្បើក តដាក សិន្ធុ អម្ពុធិ ជលធិ សមុទ្រ ។ល។ ប្រការដែលយើងគួរកត់សម្គាល់ នៅសៀមរាបគេមិនហៅអាងស្តុកទឹកទាំងអស់ថា "បារាយណ៍" នោះឡើយ ឧទាហរណ៍៖ អាងស្តុកទឹកនៅរលួសដែលមានឈ្មោះដើម "ឥន្ទ្រតដាក" អ្នកស្រុកហៅថា "តដាកលលៃ", អាងស្តុកទឹកនៅព្រះខ័ន គេហៅថា "រាលរាជដាក"។ ចំណែក នៅខេត្តកំពង់ធំវិញ អ្នកស្រុកពុំដែលហៅអាងស្តុកទឹកណាថា "បារាយណ៍" នោះឡើយ ទោះបីធំឬតូចក៏ដោយ ប៉ុន្តែគេនិយមប្រើពាក្យថា "ទន្លេ" "ខ្នារ" និង "បឹង" វិញ ហើយបើនៅព្រះវិហារវិញ គេមានហៅម្យ៉ាងទៀតថា "រហាល" ដូចយើងឃើញនៅតំបន់កោះកេរ្តិ៍។

ក្នុងវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យពន្យល់ថា "បារាយណ៍" ជាពាក្យមានប្រភពមកពីសំស្ក្រឹតមានន័យថា "ដំណើរទូទៅ, ពន្ទឹ..., ប្រទេសដែលវាលល្ហល្ហេវធំធេង, ពាក្យនេះខ្មែរយើងប្រើជាឈ្មោះ តំបន់ ខេត្រ ស្រុក ដែលវាលល្ហល្ហេវដូចយ៉ាង ស្រុកបារាយណ៍ បឹងបារាយណ៍ វាលបារាយណ៍ ជាដើម។[៩] រីឯលោកស្រី ពៅ សាវរស យល់ថា ពាក្យ "បារាយណ៍" គឺគេស្គាល់ច្រើនថាជាទឹកពិសិដ្ឋនៃតំបន់អង្គរ ហេតុដូច្នេះលោកស្រីគិតថា ពាក្យនេះទំនងក្លាយមកពីពាក្យខ្មែរបុរាណថា ***"វ្រះអន្ទ្រាយ"*** ដ្បិតលោកស្រីយល់ថា ពាក្យ "វ្រះ" ជាពាក្យពិសិដ្ឋដែលស្របជាមួយនឹងអត្ថន័យនៃបារាយណ៍ថា "ទឹកពិសិដ្ឋ"។[១០] នៅក្នុងរឿងព្រេងខ្មែរមួយដែលរៀបរាប់នៅឯកសារមហាបុរសខ្មែរនិទានថា "*បារាយណ៍ប្រុសសំដៅលើកន្លែងដែលមិនមានទឹកគឺ ថ្នល់បារាយណ៍ រីឯបារាយណ៍ស្រីសំដៅដល់កន្លែងដែលមានទឹកច្រើនគឺ បារាយណ៍ទឹកថ្លា*"។[១២]

---

[៩] *ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ៥៦៨។*
[១០] Saveros Pou 1991: 205.
[១២] Sotheavin Nhim 2018: 29-33.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

នៅក្នុងសំណេរនេះ យើងស្នើថាពាក្យ "បារាយណ៍" ដែលជាឈ្មោះរបស់ប្រាសាទដែលយើងលើកមកសិក្សានេះ គឺជាពាក្យដែលក្លាយមកពីពាក្យដើមថា ***"ព្រះនារាយណ៍"***។ ដ្បិត យើងដឹងហើយថា មាត់ខ្មែរមិននិយមហៅវែងៗដូចសំនៀងដើមសំស្ក្រឹតឡើយ ម៉្លោះហើយ ពាក្យ "ព្រះ" យើងច្រើនឮសូរថា "ប៉" ឬ "ប" (ឧទាហរណ៍ "ព្រះពុទ្ធ" ច្រើនឮថា "ប៉ពុធ") ប៉ុន្តែនៅពេលគេកត់ត្រាគេមិនបានចងចាំន័យដើមក៏អាចកត់ទៅជាពាក្យ "**បា**" ទៅវិញ។ ចំណែកឯពាក្យថា "**នារាយណ៍**" កាត់ខ្លីមកសល់ត្រឹម "**រ៉ាយ**"។ ការដែលគេហៅព្រះធាតុ (ប្រាសាទ) នេះថា "បារាយណ៍" ដូច្នេះទំនងគេសំដៅលើចម្លាក់ព្រះនារាយណ៍ផ្ទុំឆ្លាក់នៅលើផ្តែរទ្វារ ដែលគេឃើញនៅព្រះធាតុផ្ទាល់តែម្តង (រូបលេខ៧)។ ប៉ុន្តែ ក្នុងគំនិតអ្នកស្រុកដែលរស់នៅក្បែរព្រះធាតុយល់ថា តួអង្គទេពដែលយើងស្គាល់ថា "ព្រះនារាយណ៍" គឺជា "ស្តេចកន" ដែលកើតក្នុងឆ្នាំរោង (សំដៅលើនាគអនន្ត)។ ការយល់ដូច្នេះមកពីអ្នកស្រុកជាន់ក្រោយពុំស្គាល់តួអង្គនោះថាជាទេពនៃព្រហ្មញ្ញសាសនា។ មួយវិញទៀត ប្រសិនជាយើងគិតថាឈ្មោះ "បារាយណ៍" នេះសំដៅដល់អាងស្តុកទឹក ក៏ទំនងមិនអាចទៅរួចដែរ ដ្បិតនៅក្បែរព្រះធាតុពុំមានអាងស្តុកទឹកណាមានទំហំធំៗដែលអាចកត់សម្គាល់បានថាជាបារាយណ៍បានឡើយ។

ការហៅដូច្នេះពុំមែនមានតែនៅព្រះធាតុបារាយណ៍មួយទេ ពោល គឺយើងធ្លាប់ជួបនៅទីតាំងបុរាណដ្ឋានផ្សេងៗទៀតនៅទូទាំងស្រុកខ្មែរ។ ជាក់ស្តែង ទួលប្រាសាទចាស់មួយនៅមិនឆ្ងាយពីព្រះធាតុបារាយណ៍ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម អ្នកស្រុកហៅថា "**ទួលអ្នកតាតាំងរ៉ាយ**" គឺក្លាយមកពីពាក្យដើមថា "**អ្នកតាតាំងនារាយណ៍**" ដែលមានន័យថា "អ្នកតាទួលព្រះនារាយណ៍" ហើយនៅទីនោះក៏គេជួបរូបចម្លាក់ព្រះនារាយណ៍ផ្ទុំដូចគ្នាដែរ (រូបលេខ៨)។[១៣] នៅវត្តបារាយណ៍ ខេត្តកំពង់ធំវិញ ក៏មិនខុសគ្នាដែរ គឺគេហៅសំដៅលើទេពព្រះនារាយណ៍ដែលគេជួបនៅទីនោះផ្ទាល់[១៤] (រូបលេខ៩) ហើយនៅទីនោះស្រាប់ក៏គេធ្លាប់រកឃើញសិលាចារឹកនៅស.វ.ទី៧មួយ ចុះបញ្ជីលេខ K.140 ដែលរៀបរាប់អំពីតង្វាយថ្វាយដល់អាទិទេព "ឝ្រីឝង្ករណារាយណ" សម្រួលជាអក្សរខ្មែរទំនើបថា "ស្រីសង្ករណារាយណ" [១៥] (ការរួមបញ្ចូលគ្នារវាងព្រះឥសូរនិងព្រះវិស្ណុ)។ ជាងនេះទៅទៀត ភស្តុតាងកាន់តែសំខាន់មួយទៀតនោះគឺ ករណីនៅទួលបុរាណមួយក្នុងក្រុងព្រៃវែង ដែលស្ថិតនៅជាប់នឹងបឹងកំពង់ ពោល គឺគេហៅទួលនេះថា "បារាយណ៍អណ្តែត"។ ទឹកបឹងដ៏ធំ

---

[១៣] Bénisit 1965: 101.

[១៤] ម៉ង់ រ៉ាលី ២០២១: ៤៧។

[១៥] Coedès 1954: 14; Briggs 1951: 54-57.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ផេងដែលនៅជាប់នោះ អ្នកស្រុកមិនបានហៅថា "បារាយណ៍" នោះឡើយ ប៉ុន្តែគេបែរជាហៅទួលបុរាណមួយថា "បារាយណ៍អណ្តែត" ទៅវិញ ដ្បិតដោយសារពីដើមមកនៅគេធ្លាប់រកឃើញរូបចម្លាក់ព្រះនារាយណ៍តម្កល់នៅលើទីទួលនេះ ដូចមានរៀបរាប់នៅក្នុងសំណេររបស់លោក Henri Parmentier កាលពីឆ្នាំ១៩៣៥។[១៦] ក្រៅពីទីតាំងឧទាហរណ៍ទាំងអម្បាលម៉ានខាងលើនេះ ក៏នៅមានទីតាំងបុរាណដ្ឋានផ្សេងទៀតដែលគេហៅថា "បារាយណ៍" ដូចជា ប្រាសាទវត្តបារាយណ៍ (តាកែវ) ប្រាសាទបារាយណ៍ (ឧត្តរមានជ័យ) ទួលវត្តបារាយណ៍ជាន់ដែក (កំពង់ធំ) ទួលបារាយណ៍ (ស្រុកប្រាសាទបល្ល័ង្គ កំពង់ធំ)។ ដោយឡែក នៅខេត្តសៀមរាបវិញ ពាក្យ "បារាយណ៍" នោះ ទំនងការហៅពីមុនមកមិនសំដៅដល់អាងស្តុងទឹកនោះទេ តែទំនងគេហៅសំដៅលើរូបព្រះនារាយណ៍ផ្ទុំដែលឆ្លាក់នៅលើថ្មគោលមួយ រកឃើញនៅប្រាសាទមេបុណ្យខាងលិច (រូបលេខ១០) ឬក៏អាចជារូបព្រះនារាយណ៍ផ្ទុំធ្វើអំពីសំរិទ្ធដ៏ធំដែលរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញក៏ថាបាន (រូបលេខ១១)។ រីឯនៅបារាយណ៍ខាងកើត ដែលគេហៅថា "ថ្នល់បារាយណ៍" ក៏ទំនងសំដៅលើរូបព្រះនារាយណ៍ដែលរកឃើញនៅទីនោះដូចគ្នា (រូបលេខ១២)។

ជារួមមក ឈ្មោះ "ព្រះធាតុបារាយណ៍" ទំនងមានន័យថា "ប្រាសាទព្រះនារាយណ៍" ដ្បិតពាក្យ "ព្រះធាតុ" គឺមានន័យថាចេតិយ ដែលអ្នកស្រុកសំដៅលើប្រាសាទ។ ចំណែក "បារាយណ៍" ទំនងវិវឌ្ឍមកពីពាក្យថា "ព្រះនារាយណ៍"។



រូបលេខ១-២៖ ព្រះធាតុបារាយណ៍ (មើលពីទិសឦសាន និងខាងលិច)



រូបលេខ៣-៤៖ ចម្លាក់ព្រះឥសូរពាំ និងចម្លាក់កូរសមុទ្រទឹកដោះ នៅព្រះធាតុបារាយណ៍

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

[១៦] Parmentier 1935: 46-47.



រូបលេខ២៥-២៦៖ ចម្លាក់ពាលីនិងសុគ្រីពប្រយុទ្ធគ្នា និងចម្លាក់ព្រះក្រឹស្ណទ្រភ្នំគោវធ៌ន នៅព្រះធាតុបាពាយណ៍



រូបលេខ២៧៖ ចម្លាក់ព្រះនារាយណ៍ផ្ទុំលើនាគអនន្ត នៅព្រះធាតុបាពាយណ៍





រូបលេខ២៨៖ ចម្លាក់ព្រះនារាយណ៍ផ្ទុំ នៅទួលអ្នកតាតាំងពាយ

(ប្រភព៖ EFEO)

រូបលេខ២៩៖ បដិមាព្រះនារាយណ៍ នៅវត្តបាពាយណ៍

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ ចម្លាក់ព្រះនារាយណ៍លើថ្មគោលនៅ ប្រាសាទមេបុណ្យខាងលិច (ប្រភព៖ EFEO)



រូបលេខ១២៖ បដិមាព្រះនារាយណ៍រកឃើញនៅ ថ្នល់បារាយណ៍ ខេត្តសៀមរាប (ប្រភព៖ EFEO)



រូបលេខ១១៖ ចម្លាក់ព្រះនារាយណ៍ផ្ទុំធ្វើអំពីសំរិទ្ធ រកឃើញនៅប្រាសាទមេបុណ្យ ខាងលិច ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ (ប្រភព៖ EFEO)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង


**ព្រាប ចាន់ម៉ារ៉ា**

២០១២, *"ពាក្យប្រើចំពោះសំណង់បុរាណ និងក្បាច់លម្អ" ភ្នំពេញ*

**ម៉ង់ វ៉ាលី**

២០២១, *"កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ" ភ្នំពេញ*

**ពុទ្ធសាសនបណ្ឌិត**

១៩៦៧, "**វចនានុក្រមខ្មែរ**", ភ្នំពេញ

**Bénisti, Mireille**

1965, Représentations khmère de Visnu couché, *Arts Asiatique*, Vol 11, Paris

**Boisselier, Jean**

1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris

**Briggs, Lawrence Palmer**

1951, "*The ancient Khmer empire*", New York

**Coedès, George**

1954, "*Inscription du Cambodge"*, Vol VI, Hanoi

**Dalet, Rober**

1936, "Recherches archéologiques au Cambodge", *BEFEO*, Vol 36, No.1, Paris

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Nhim Sotheavin**

2018, *A study of the names of monuments in Angkor (Cambodia)*, Tokyo

**Parmentier, Henri**

1935, "Complément à l'inventaire descriptive des monuments du Cambodge", *BEFEO*, 35, Paris

**Randhawa, M.S**

1956, *The Krishna legend in Pahari Painting,* New Delhi

**Roveda, Victorio**

2005, "*Image of the gods*", Bangkok

**Saveros Pou**

1991, "Les noms de monuments khmers", *BEFEO*, Vol 78, Paris

**Thomas, Paul**

1999, *"Epics, Myths and Legends of India*", Treasure House of Books, Boomba